# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស បកប្រែជា ភាសាខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2014, 15:54
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿងលេខ ០០២/០២

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

គង់ ផល្លៈ

ឡោ ជុនធី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យ៉ុង ផានិត

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Olivier BAHOUGNE
Pascal AUBOIN
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Jeanne SULZER
Philippine SUTZ

Andrew CAYLEY

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGES

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Beini YE

## I. សេចក្តីផ្តើម និងប្រវត្តិសាស្ត្រនីតិវិធី

១. នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ភស្តុតាងទាំងអស់ដែលបានទទួលយកក្នុងសំណុំរឿង០០២/០១ និងបានផ្តល់តម្លៃជាលេខ E3 ត្រូវបានដាក់ជូនដោយត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ ដើម្បីគោលបំណងឱ្យកិច្ចដំណើរការនីតិវិធីសវនាការទាំងអស់នាពេលអនាគត" និងសម្រេចថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយ ដែលបានស្តាប់សក្ខីកម្មក្នុងសំណុំរឿង០០២/០១ អាចនឹងត្រូវបានកោះហៅម្តងទៀតនៅក្នុងការជំនុំជម្រះ [នៃ] សំណុំរឿង០០២/០២ បានតែក្នុង ករណីបើមានភាគីនានាដែលស្នើសុំបំពេញគ្រប់តាមលក្ខខណ្ឌជូនតុលាការថាការសាកសួរដេញដោលបន្ថែមទៀត គឺដើម្បីផលប្រយោជន៍យុត្តិធម៌ប៉ុណ្ណោះ។"[1] នៅក្នុងការគាំទ្រសំណើរបស់ពួកគេ សហព្រះរាជអាជ្ញា បានកត់សម្គាល់នូវសារៈសំខាន់នៃដំណោះស្រាយដំបូងមួយនៅក្នុងផលប្រយោជន៍នៃការធានានូវកិច្ចដំណើរការនីតិវិធីដែលមានប្រសិទ្ធភាព។[2]

២. នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ មេធាវីការពារក្តីរបស់លោកខៀវ សំផន បានដាក់ការឆ្លើយតបរបស់ខ្លួន ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទាត់ចោលសំណើសុំទាំងស្រុងរបស់ព្រះរាជអាជ្ញាដោយអាស្រ័យហេតុថា វារំលោភទៅលើវិធាននីតិវិធីជាមូលដ្ឋាន និងមិនអើពើអំពីផលវិបាកនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២ ទៅលើការប្រើប្រាស់ភស្តុតាងនៃសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២។[3]

---

[1] E302, ការ ដាក់ស្នើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រើនៃភស្តុតាងនិងនីតិវិធីសម្រាប់ការកោះហៅម្តងទៀតនូវសាក្សីពីសំណុំរឿង ០០២/០ ក្នុងសំណុំរឿង ០០២/០២, ១៥ ខែមករា ឆ្នាំ២០១៤, para 1 ។

[2] *ដូចខាងលើ*

[3] E302/1 ចម្លើយរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹង "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មីពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង ០០២/០២", ២៧ ខែមករា ឆ្នាំ២០១៤

៣. ដើមបណ្តឹងរដ្ឋប្បវេណីសូមគាំទ្រដល់ការដាក់ស្នើរបស់សហព្រះរាជអាជ្ញាលើការប្រើប្រាស់ភស្តុតាងនៃសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២ និងបន្តជម្រុញឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់សេចក្តីសម្រេចមួយលើសំណើ នេះ ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។

## II. ទឡ្ហីករណ៍

៤. បំពេញបន្ថែមនូវអំណះអំណាងដែលបានដាក់ចេញដោយព្រះរាជអាជ្ញា ភាគីដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានវិធីសាស្ត្រដែលត្រូវនឹងស្ថានភាពជាក់ស្តែង និងសមហេតុផល ឆ្លើយតបទៅនឹងភស្តុតាងដែលគោរពតាមការពិចារណាលើសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌ និងពិចារណាលើអាយុ និងលក្ខខណ្ឌរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទ្ទឹងរង់ចាំការកាត់ក្តីលើបទឧក្រិដ្ឋដែលបានចោទប្រកាន់ទាំងនេះ អស់រយៈពេលជាង ៣៥ឆ្នាំ មកហើយ សាលក្រមដែលមានភាពយឺតយ៉ាវយ៉ាងខ្លាំងនឹងអាចមិនផ្តល់យុត្តិធម៌អ្វីទាល់តែសោះដល់អ្នកទាំងឡាយដែលមានវ័យចំនាស់ ឬពិការ។

៥. ការសម្រេចចិត្តដំបូង និងច្បាស់លាស់ពីអង្គជំនុំជម្រះសាលាដំបូងលើការប្រើប្រាស់ភស្តុតាងនៃសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២ នឹងជួយដល់ភាគីទាំងអស់ក្នុងការរៀបចំសម្រាប់ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២។ សេចក្តីសម្រេចនេះគឺមានសារៈសំខាន់ផងដែរ ដើម្បីផ្តល់ជូនមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នូវភាពច្បាស់លាស់អំពីបញ្ហាដែលនឹងមានផលប៉ះពាល់ខ្លាំងទៅលើប្រសិទ្ធផល និងការកំណត់ពេលវេលានៃកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២/០២។ ការណែនាំ យ៉ាងច្បាស់លាស់ទៅលើបញ្ហានេះពីសំណាក់អង្គជំនុំជម្រះសាលាដំបូងនឹងអនុញ្ញាតឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីបានកាន់តែប្រសើរ អំពីអ្វីដែលពួកគេអាចរំពឹងទុកនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២។

**ដោយផ្អែកលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ** ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. **ធ្វើសេចក្តីសម្រេច**ជាបន្ទាន់លើបញ្ហាការប្រើប្រាស់ភស្តុតាងនៃសំណុំរឿង ០០២/០១ នៅក្នុងសំណុំរឿង ០០២/០២

ខ. **បង្គាប់ថា** រាល់ភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានដាក់យ៉ាងត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ និងកិច្ចដំណើរការនីតិវិធីសវនាការទាំងអស់នាពេលអនាគត និង

គ. **សម្រេច**កោះហៅ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយនៃសំណុំរឿង ០០២/០១ បានតែក្នុងករណីដែល ភាគីស្នើសុំបំពេញគ្រប់តាមលក្ខខណ្ឌជូនតុលាការថា ការសួរដេញដោលបន្ថែមទៀត គឺដើម្បីផលប្រយោជន៍យុត្តិធម៌ប៉ុណ្ណោះ។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំរបស់យើងខ្ញុំដោយសេចក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | [signature] |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | Montpellier | [signature] |